ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការក្នុងក្របខណ្ឌ

## អង្គភាពប្រឆាំងអំពើពុករលួយ

## ក្រសួងសាធារណការ និងដឹកជញ្ជូន

## និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រាប់ក្របខណ្ឌឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៥៥៦/២៤ មស.សរណ

ថ្ងៃអង្គារ ១១កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌអង្គភាពប្រឆាំងអំពើពុករលួយ** សូមជូនដំណឹង ដល់បេក្ខជនដែលបានដាក់ពាក្យប្រឡងប្រជែងជ្រើសរើសក្របខណ្ឌថ្មី ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌអង្គភាពប្រឆាំងអំពើពុករលួយ ទាំងអស់ឱ្យបានជ្រាបថា គណៈកម្មការរៀបចំការប្រឡងប្រជែង នឹងរៀបចំដំណើរការប្រឡងប្រជែង ប្រព្រឹត្តទៅដូចខាងក្រោម៖

ក- សម័យប្រឡង ៖ ថ្ងៃអាទិត្យ ទី៣ ខែមីនា ឆ្នាំ២០២៤

ខ- មណ្ឌលប្រឡង ៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ទីតាំងស្ថិតតាមបណ្តោយមហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ)

គ- វិញ្ញាសាប្រឡង ៖ បេក្ខជនត្រូវប្រឡងមុខវិជ្ជា ពាក់ព័ន្ធនឹង ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់មួយចំនួនទៀត រួមទាំងការវិភាគបទល្មើស ចំណេះដឹងទូទៅ ភាសាបរទេស និងកុំព្យូទ័រ

ឃ-រយៈពេលប្រឡង ៖ ការប្រឡងមានរយៈពេល ១២០នាទី (ចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៦:០០នាទី)។

**បញ្ជាក់៖**

១. បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង ១ម៉ោងមុនការប្រឡង(ម៉ោង១៣:០០នាទី) ព្រមទាំងភ្ជាប់មកជាមួយនូវ៖

- សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

២. សៀវភៅច្បាប់ត្រូវបានអនុញ្ញាតឱ្យយកចូលក្នុងមណ្ឌលប្រឡង

៣. បេក្ខជនមិនត្រូវយកឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ ទូរស័ព្ទ នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

៤. សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៥៥៨/២៤ មស.សជណ

ថ្ងៃ សុក្រ ១១កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** សូមជូនដំណឹងដល់បេក្ខជន ដែលបានដាក់ពាក្យចូលរួមការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២៣ ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ ត្រូវចូលរួមការប្រឡង ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

ក-សម័យប្រឡង និងមណ្ឌលប្រឡង

-សម័យប្រឡងថ្ងៃអង្គារ ទី៥ ខែមីនា ឆ្នាំ២០២៤

-មណ្ឌលប្រឡង សាលាភូមិន្ទរដ្ឋបាល (ទីតាំងស្ថិតតាមបណ្តោយវិថីឧកញ៉ាញឹកជូឡុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ)

ខ-វិញ្ញាសាប្រឡង

- វិញ្ញាសាចំណេះដឹងទូទៅ (សំណួរពហុចម្លើយពាក់ព័ន្ធនឹងរដ្ឋបាល មុខងារសាធារណៈ ក្រមសីលធម៌, វប្បធម៌ទូទៅ, ព័ត៌មានវិទ្យា) "រយៈពេល ១ម៉ោង" (ម៉ោង១២៖៣០នាទី ដល់ម៉ោង ១៣៖៣០នាទី) មេគុណ១

- វិញ្ញាសាជំនាញ "រយៈពេល ២ម៉ោង" (ម៉ោង១៤៖០០នាទី ដល់ម៉ោង ១៦៖០០នាទី) មេគុណ២

-វិញ្ញាសាភាសាអង់គ្លេស "រយៈពេល១ម៉ោង"( ម៉ោង១៦៖៣០នាទីដល់ម៉ោង១៧៖៣០នាទី) មេគុណ១។

**<u>បញ្ជាក់៖</u>**

**+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង ១ម៉ោងមុនការប្រឡង(ម៉ោង១១៖៣០នាទី) និងភ្ជាប់មកជាមួយនូវ៖**

១-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

២-ប៊ិចពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៥៥៧/២៤ មស.សាជណ

ថ្ងៃ អង្គារ ១១កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូន** សូមជូនដំណឹងដល់បេក្ខជន ដែលបានដាក់ពាក្យចូលរួមការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០២៣ ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ ត្រូវចូលរួមការប្រឡង ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

ក-សម័យប្រឡង និងមណ្ឌលប្រឡង

-សម័យប្រឡងថ្ងៃចន្ទ ទី៤ ខែមីនា ឆ្នាំ២០២៤

-មណ្ឌលប្រឡង សាលាភូមិន្ទរដ្ឋបាល (ទីតាំងស្ថិតតាមបណ្តោយវិថីឧកញ៉ាញឹកជូឡុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ)

ខ-វិញ្ញាសាប្រឡង

- វិញ្ញាសាចំណេះដឹងទូទៅ (សំណួរពហុចម្លើយពាក់ព័ន្ធនឹងរដ្ឋបាល មុខងារសាធារណៈ ក្រមសីលធម៌, វប្បធម៌ទូទៅ, ព័ត៌មានវិទ្យា) "រយៈពេល ១ម៉ោង" (ម៉ោង១២៖៣០នាទី ដល់ម៉ោង ១៣៖៣០នាទី) មេគុណ១
- វិញ្ញាសាជំនាញ "រយៈពេល ២ម៉ោង" (ម៉ោង១៤៖០០នាទី ដល់ម៉ោង ១៦៖០០នាទី) មេគុណ៣
- វិញ្ញាសាភាសាអង់គ្លេស "រយៈពេល១ម៉ោង"( ម៉ោង១៦៖៣០នាទីដល់ម៉ោង១៧៖៣០នាទី ) មេគុណ១។

**<u>បញ្ជាក់</u>៖**

+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង ១ម៉ោងមុនការប្រឡង(ម៉ោង១១៖៣០នាទី) និងភ្ជាប់មកជាមួយនូវ៖

១-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

២-ប៊ិចពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**